**កម្ពុជា: អង្គការសហប្រជាជាតិ ជម្រុញឱ្យមានការស៊ើបអង្កេតជាបន្ទាប់លើករណីនៃការប្រើប្រាស់កម្លាំងហួសហេតុ ដោយកងកម្លាំងសន្តិសុខ**

**១៥ វិច្ឆិកា ២០១៣** - ការប៉ះទង្គិចគ្នាមួយនៅពេលថ្មីៗនេះ នៅកម្ពុជា ក្នុងនោះ គេបានមើលឃើញនគរបាលវាយដំទៅលើបាតុករដោយប្រើដំបង បាញ់គ្រាប់កាំភ្លើងពិត និងគ្រាប់កាំភ្លើងជ័រ ស្ថិតក្នុងចំងាយជិត ដែលករណីនេះ ត្រូវតែឲ្យមានស៊ើបអង្កេតជាបន្ទាន់ ដើម្បីធានាសមមាត្រាទាំងស្រុង ចំពោះការប្រើកំលាំងហួសហេតុ នេះបើតាមការិយាល័យសិទ្ធិមនុស្សអង្គការសហប្រជាជាតិ បានឱ្យដឹងនៅថ្ងៃនេះ។

ថ្លែងទៅកាន់អ្នកសារព័ត៌មាននៅទីក្រុងហ្សឺណែវ លោក រ៉ូភើត ខូវីល (Rupert Colville) អ្នកនាំពាក្យនៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស (OHCHR) បានសំដែងការព្រួយបារម្ភជាខ្លាំង អំពីការប៉ះទង្គិចគ្នាដោយហឹង្សា ដែលបានកើតឡើង នៅខ័ណ្ឌស្ទឹងមានជ័យ រាជធានីភ្នំពេញ នៅថ្ងៃទី១២ ខែវិច្ឆិកា កន្លងមកនេះ ។

ការប៉ះទង្គិចគ្នានេះ បានចាប់ផ្ដើមកើតមាន បន្ទាប់ពីកម្មកររោងចក្រកាត់ដេរ ត្រូវគេរារាំងមិនឲ្យដើរជាក្បួនទៅកាន់លំនៅដ្ឋានរបស់លោកនាយករដ្ឋមន្ត្រី ដែលពួកគេគ្រោងនឹងធ្វើបាតុកម្មនៅទីនោះ នេះបើប្រសាសន៍របស់លោក រ៉ូភើត ខូវីល (Rupert Colville)។

" ប្រជាពលរដ្ឋម្នាក់ ដែលឈរនៅជិតទីនោះ ត្រូវបានគេបាញ់ស្លាប់ និងប្រជាពលរដ្ឋជាច្រើននាក់ទៀត ត្រូវរងរបួសធ្ងន់ធ្ងរ នៅក្នុងអំឡុងពេលនៃការប៉ះទង្គិចគ្នានេះ ដែលបានកើតមានបន្ទាប់ពីការចូលរួមរបស់បាតុករជនស៊ីវិល ដែលដំបូងឡើយ មិនបានចូលរួមក្នុងការតវ៉ានោះ និងកម្លាំងនគរបាល និងតម្រួតយោធារាជធានីភ្នំពេញ” លោក ខូវីល បានបញ្ជាក់ដូច្នេះ។

“ គេបានឃើញនគរបាលវាយដំលើប្រជាពលរដ្ឋ ដោយដំបង បាញ់គ្រាប់កាំភ្លើងពិត និងគ្រាប់កាំភ្លើងជ័រ ស្ថិតក្នុងចំងាយជិត” ។

“ លោកបានបន្ថែមទៀតថា ខណៈពេលដែល មនុស្សភាគច្រើនបំផុតក្នុងចំណោមមនុស្ស ៣៨ ដែល ត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលនៃការប៉ះទង្គិចគ្នានេះ បច្ចុប្បន្នត្រូវបានដោះលែងឲ្យមានសេរីភាពវិញហើយនោះ មានសេចក្ដីរាយការណ៍ថា មានអនីតិជនពីររូប ម្នាក់អាយុ ១៤ ឆ្នាំ និងម្នាក់ទៀតអាយុ១៧ ឆ្នាំ កំពុងស្ថិតក្នុងការឃុំខ្លួននៅឡើយ។

ឧប្បត្តិហេតុថ្មីបំផុតនេះ កើតមានបន្ទាប់ពីការប៉ះទង្គិចគ្នាកន្លងមក ដែលបានកើតឡើង ក្នុងខែកញ្ញា នៅជិតស្ពានព្រះមុនីវង្ស រាជធានីភ្នំពេញ ជាកន្លែងដែលកងកម្លាំងនគរបាល កងរាជអាវុធហត្ថ បានបាញ់ទៅលើហ្វូង

មនុស្សនៅចំណុចបិទផ្លូវ ដែលបណ្តាលឲ្យប្រជាពលរដ្ឋម្នាក់ស្លាប់ និងប្រជាពលរដ្ឋជាច្រើននាក់ទៀតបានរងរបួស។

"យើងកំពុងធ្វើការតាមដានករណីនេះ ជាមួយអាជ្ញាធរពាក់ព័ន្ធ និងជម្រុញឱ្យពួកគេ បើកការស៊ើបអង្កេតជាបន្ទាន់ និងទាំងស្រុងលើករណីនៃការប៉ះទង្គិចទាំងនេះ ដើម្បីធានាគណនេយ្យភាពពេញលេញរបស់សមាជិកនៃកងកម្លាំងសន្តិសុខណាដែលបានរកឃើញថា បានប្រើប្រាស់កម្លាំងហួសហេតុ និងមិនសមាមាត្រ នេះបើតាមប្រសាសន៍របស់ លោក លោក ខូវីល ។

"យើងក៏ជម្រុញផងដែរ ឱ្យអាជ្ញាធរពាក់ព័ន្ធ ធ្វើឲ្យប្រាកដថា អនីតិជនដែលបានចាប់ខ្លួន ត្រូវបានប្រព្រឹត្តសមស្របទៅនឹងអាយុរបស់ពួកគេ និងអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។”

ទន្ទឹមនេះ យើងសូមស្នើផងដែរ ឲ្យក្រុមអ្នកតវ៉ា ធ្វើឲ្យប្រាកដថា បាតុកម្មត្រូវបានធ្វើដោយសន្តិវិធី ការិយាល័យ OHCHR សូមអំពាវនាវផងដែរ ដល់អាជ្ញាធរ ដើម្បីធានាថា សេរីភាពក្នុងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី ដែលបានគោរពយ៉ាងពេញលេញ។

ចប់